# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសំរបសំរួល រៀបចំ សិក្ខាសាលាអន្តរជាតិភូមិភាគអាស៊ីអគ្នេយ៍ស្តីពីបញ្ហាមីន

៚៚៚៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសំរបសំរួល រៀបចំ សិក្ខាសាលាអន្តរជាតិ ភូមិភាគអាស៊ីអគ្នេយ៍ ស្តីពីបញ្ហាមីនដែលមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| ១. ឯកឧត្តម សុខ អាន | ប្រធាន |
| ២. ឯកឧត្តម នាយឧត្តមសេនីយ៍ ហុក ឡុងឌី | អនុប្រធាន |
| ៣. ឯកឧត្តម សម សុគ្គា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. ឯកឧត្តម ខឹម សោភ័ណ | អនុប្រធាន |
| ៥. ឯកឧត្តម មិន ឃិន | សមាជិក |
| ៦. ឯកឧត្តម ឧត្តមសេនីយ៍ឯក មល់ រឿប | សមាជិក |
| ៧. ឯកឧត្តម ឧត្តមសេនីយ៍ទោ យូ ស៊ិនឡុង | សមាជិក |
| ៨. ឯកឧត្តម ស៊ូ គីរិទ្ធ | សមាជិក |

**ប្រការ ២ ៖** គណៈកម្មការអន្តរក្រសួងមានភារកិច្ច រៀបចំរាល់ឯកសារពាក់ព័ន្ធ ពិនិត្យសំរបសំរួលលើខ្លឹមសារបទបង្ហាញ ដើម្បីញ៉ាំងអោយប្រធានបទនីមួយៗ មានភាពរលូន ត្រៀមរៀបចំទស្សនកិច្ចនៅមជ្ឈមណ្ឌលហ្វឹកហ្វឺនខេត្តកំពង់ឆ្នាំង និង សៀមរាប លើកបង្ហា តាំងពិពណ៌រូបភាពពីសមិទ្ធិផលនៃកិច្ចប្រតិបត្តិការសកម្មភាពមីន និង កិច្ចសង្គ្រោះជនពិការដោយសារមីន ចាត់ចែងយកពត៌មាន ផ្សព្វផ្សាយទូលំទូលាយ និង ចាត់តាំងកម្លាំងការពារសុវត្ថិភាព និងពិធីការ ក្នុងដំណើរការអង្គសិក្ខាសាលា និង ទស្សនៈកិច្ចនានា ។

**ប្រការ ៣ ៖** គណៈកម្មការនេះមានអនុគណៈកម្មការចំនួន ៤ សំរាប់ជំនួយការងារ

១. អនុគណៈកម្មការរៀបចំខ្លឹមសារៈ

| | |
|---|---|
| ១. ឯកឧត្តម សម សុត្ថា | ប្រធាន |
| ២. ឯកឧត្តម ខឹម សោភ័ណ | អនុប្រធាន |
| ៣. ឯកឧត្តម ធីយ រឿន | អនុប្រធាន |
| ៤. លោក វ៉ឹក ផេង | សមាជិក |
| ៥. លោក អេង យេង | សមាជិក |
| ៦. លោកស្រី ម៉ែន នារីសោភ័គ | សមាជិក |
| ៧. លោក ជា អៀង | សមាជិក |
| ៨. លោក ថោ ផេង្គា | សមាជិក |

២. អនុគណៈកម្មការសន្តិសុខៈ

| | |
|---|---|
| ១. ឯកឧត្តម ឧត្តមសេនីយ៍ឯក នេត សាវឿន | ប្រធាន |
| ២. ឯកឧត្តម ឧត្តមសេនីយ៍ឯក មល់ រឿប | អនុប្រធាន |
| ៣. ឯកឧត្តម ឧត្តមសេនីយ៍ទោ យូ ស៊ុនឡុង | សមាជិក |
| ៤. លោក ឧត្តមសេនីយ៍ត្រី ស៊ឹម សុផល | សមាជិក |

៣. អនុគណៈកម្មការពត៌មានៈ

| | |
|---|---|
| ១. លោក ខៀវ ថវិកា | ប្រធាន |
| ២. លោក ឡេង សុជា | សមាជិក |
| ៣. លោក ចាន់ រង្គា | សមាជិក |

៤. អនុគណៈកម្មការពិធីការៈ

| | |
|---|---|
| ១. ឯកឧត្តម ជា សុខុម | ប្រធាន |

២. លោក ឧត្តមសេនីយ៍ត្រី សែម សុវណ្ណនី អនុប្រធាន

៣. លោក ហេង រតនា អនុប្រធាន

៤. លោក ម៉ោញ សំអាត សមាជិក

៥. លោក នេត សុផល សមាជិក

**ប្រការ ៤ :** សមាជិកគណៈកម្មការ និង អនុគណៈកម្មការទាំងអស់ខាងលើនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥ :** គណៈកម្មការនេះ មានលេខាធិការដ្ឋានមួយ នៅអគ្គលេខាធិការដ្ឋាន អាជ្ញាធរមីន ដើម្បីសំរបសំរួលការងារប្រចាំថ្ងៃ ។

**ប្រការ ៦ :** គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពត៌មាន អគ្គស្នងការនគរបាលជាតិ អគ្គលេខាធិការអាជ្ញាធរមីន អគ្គលេខាធិការគណៈកម្មាធិការបុណ្យជាតិ-អន្តរជាតិ អគ្គលេខាធិការកាកបាទក្រហមកម្ពុជា អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អភិបាលក្រុងភ្នំពេញ អភិបាលខេត្តកំពង់ឆ្នាំងគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនឹងសាមីខ្លួន ដែលមានចែងក្នុងប្រការ ១ និង ប្រការ ៣ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ខែ កុម្ភៈ ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១ និង ប្រការ៣
- ឯកសារ-កាលប្បវត្តិ